# ៣១ - រឿង បុរសជីកក្ដាម



Top-Tablets bei o2
Exklusive Tablets mit o2 Go Flat. Jetzt günstig mobil bei o2 sichern.

និទាន ១ ថា : មានបុរសប្ដីប្រពន្ធ មានកូនប្រុសមួយ កូននោះអាយុបាន ១២ ឆ្នាំ មាតាស្លាប់ទៅ នៅតែឪពុកពោះម៉ាយ ។ ឪពុកក៏ធ្វើរបរលក់ដូរតែពីរនាក់នឹងកូន លក់មិនដាច់រឹតតែក្រទៅៗ ក្រោយមក ឪពុកអនិច្ចកម្មទៅទៀត នៅតែកូនម្នាក់ឯងរក្សាផ្ទះសំបែង ។ ឪពុកស្លាប់ទៅបាន ៥ ថ្ងៃក៏មកពន្យល់សប្ដិថា «កូនឯងក្រលំបាកណាស់ យើងជាឪពុកគ្មានរបស់អ្វីនឹងឲ្យទេ ដូច្នេះឲ្យកូនទៅជីកក្ដាមនៅក្រោមខ្នមអ្នកតា នាទិសឰសានផ្ទះយើង យកទៅលក់ចិញ្ចឹមជីវិតរៀងរាល់ថ្ងៃចុះ វេលាព្រឹក ថ្ងៃរះឡើងកាលណាឲ្យកូនទៅជីកយករាល់ថ្ងៃកុំខាន » ។ លុះភ្លឺច្បាស់ កូននោះភ្ញាក់ឡើង ចាំជាក់នូវនិមិត្តសព្វគ្រប់ ក៏ចាប់យកចបដើរតម្រង់ទៅខ្នមអ្នកតា ជីកទៅឃើញក្ដាមមួយប្រាកដមែន រួចយកក្ដាមនោះទៅលក់ឲ្យអ្នកផ្សារៗ ក៏ទិញយក ។ បុរសនោះបានប្រាក់ហើយត្រឡប់មកវិញ ។ ថ្ងៃក្រោយវេលាព្រឹក បុរសទៅជីកក្ដាមនៅកន្លែងដដែលនោះ បានក្ដាមមួយយកទៅលក់ឲ្យអ្នកផ្សារ គេក៏ទិញយកទៅទៀត ។ បុរសនោះត្រឡប់មកផ្ទះវិញ ។ នៅទីនោះ មានមហាសេដ្ឋីម្នាក់មានកូនស្រីក្រមុំច្រើន កូនស្រីបងៗទាំងប៉ុន្មាន មហាសេដ្ឋីរៀបឲ្យមានប្ដីអស់ នៅតែកូនស្រីពៅម្នាក់ ឈ្មោះនាងពៅប្រកែកមិនព្រមយកប្ដី សូម្បីមហាសេដ្ឋីជាឪពុកម្ដាយ បង្ខំឲ្យមានប្ដីម្ដេចម្ដា ក៏នាងមិនព្រម ។ រីឯបុរសនោះ លុះថ្ងៃក្រោយ ទៅជីកក្ដាមនៅទីកន្លែងដដែលបានមួយទៀត ហើយកាន់យកទៅលក់ ។ នាងពៅកូនក្រមុំមហាសេដ្ឋីបានឃើញ ក៏ហៅមកសួរថា « អ្នកកំឡោះ យួរក្ដាមទៅណា ? » ។ បុរសនោះជម្រាបថា « ខ្ញុំយកទៅលក់ » ។ នាងពៅក៏ទិញយក ហើយនាងប្រាប់ថា « ពីថ្ងៃនេះទៅ បើអ្នកបានក្ដាម កុំលក់ឲ្យអ្នកណា ត្រូវអ្នកយកមកលក់ឲ្យខ្ញុំ រាល់ថ្ងៃកុំខាន » ។ ដែលទៅជាយ៉ាងនេះ ដោយនាងនោះមានចិត្តប្រតិព័ទ្ធនឹងបុរសនោះណាស់ តែអ្នកនោះមិនដឹងខ្លួនទេ ។ បុរសនោះបានប្រាក់ហើយត្រឡប់មកផ្ទះវិញ ។ ថ្ងៃក្រោយបុរសនោះ ទៅជីកក្ដាមនៅទីកន្លែងដដែលបានទៀត រួចយកមកលក់ឲ្យតែនាងពៅនោះរាល់ៗថ្ងៃ ។ នាងពៅក៏ចេះតែទទួលទិញយកក្ដាមមិនដែលខាន ហើយមានចិត្តរឹតតែស្រឡាញ់បុរសនោះខ្លាំងឡើង ក៏ធ្វើឫកពាកិរិយាឲ្យបុរសនោះដឹង ។ បុរសនោះដឹងជាក់ថា « នាងនោះស្រឡាញ់ខ្លួនប្រាកដ » តែដោយពិចារណាថា សព្វថ្ងៃនេះខ្លួនជាអ្នកក្រីក្រលំបាកណាស់ ហើយកំព្រាផង ក៏មិនហ៊ាននិយាយថាម្ដេចឡើយ ។ ចំណែកបងស្រីៗប៉ុន្មាននាក់ បានឃើញនាងពៅជាប្អូន ធ្វើឫកពាកិរិយាស្រឡាញ់បុរសលក់ក្ដាមនោះពន់ពេក ក៏នាំគ្នាទៅជម្រាបមហាសេដ្ឋីជាមាតាបិតា « នាងពៅជាប្អូន ធ្វើឫកពាស្រឡាញ់បុរសជីកក្ដាមនោះក្រៃពេក បុរសនោះបានក្ដាមយកមកលក់ឲ្យតែនាងពៅ ឯនាងពៅចេះតែទទួលទិញរាល់តែថ្ងៃ រួចធ្វើឫកពាកិរិយាស្រឡាញ់បុរសនោះណាស់ ទោះបីខ្ញុំទាំងអស់គ្នា និយាយទូន្មានដូចម្ដេច ក៏មិនស្ដាប់មិនតាម រឹតតែធ្វើខ្លាំង » ។ សេដ្ឋីជាបិតាមាតា ឮដូច្នោះខឹងប្រឡោតឲ្យហៅនាងពៅមកជេរបន្ទោស ត្មះតិះដៀលថា «ហងនេះ ជាមនុស្សរឹងត្អឹងទទឹងនឹងចិត្តមាតាបិតា អញឲ្យមានប្ដីទៅមនុស្សមានទ្រព្យសម្បត្តិ ហងឯងប្រកែកមិនព្រមយក ឥឡូវហងស្រឡាញ់អាមនុស្សកម្សត់លក់តែក្ដាមវិញ ហងឯងនេះអាក្រក់ណាស់ ចុះចេញពីផ្ទះអញឲ្យឆាប់ទៅយកអាកម្សត់លក់ក្ដាមនោះចុះ, ចាប់ពីថ្ងៃនេះទៅហងឯង កុំមកឡើងផ្ទះអញ សូម្បីតែក្នុងភូមិក៏ចូលមិនបាន អញកាត់ចោលហើយ » ។ ចំណែកមាតាកាត់ចិត្តមិនដាច់ពីកូនពៅ ក៏លបវេចរបស់ស្រាលៗ ដែលមានតម្លៃឲ្យនាងពៅជាកូន ។ នាងពៅក៏សំពះលាមាតាយកបង្វេចដែលមាតាឲ្យនោះ ចុះចេញពីផ្ទះ សំដៅទៅផ្ទះ

បុរសលក់ក្តាម និយាយពីរឿងដែលបិតាខឹងបណ្តេញសព្វគ្រប់ ប្រាប់បុរសនោះៗ បានស្តាប់ហើយ ឆ្លើយតបថា « សព្វថ្ងៃ ខ្លួនខ្ញុំនេះក្រីក្រជាទីបំផុត ហើយកំព្រាតែម្នាក់ឯងផង នាងត្រឡប់ទៅវិញចុះខ្ញុំមិនហ៊ានទទួលយកនាងទេ ខ្ញុំខ្លាចមហាសេដ្ឋីជាបិតានាងចាប់ទោស យកខ្ញុំទៅសម្លាប់» ។ នាងពៅតបថា «ខ្ញុំមិនទៅវិញទេ ស៊ូស្លាប់នឹងអ្នកហើយ ! » ។ បុរសនោះសួរថា « បើដូច្នេះយើងគិតដូចម្តេច ? » ។ នាងពៅឆ្លើយថា « បើអ្នកគិតឃើញយ៉ាងណា ខ្ញុំទទួលធ្វើតាមយ៉ាងនោះទាំងអស់ » ។ បុរសនោះ នាំនាងពៅចេញចោលផ្ទះ ទៅនៅស្រុកក្រៅ ហើយធ្វើផ្ទះ ១ ខ្ទងសម្រាប់ លុះព្រឹកឡើងមកដឹកក្តាមនៅទីដដែល យកទៅលក់ដូចថ្ងៃមុនទៀត បានប្រាក់ហើយទិញវត្ថុផ្សេងៗផ្ញើប្រពន្ធ ហើយប្រព្រឹត្តយ៉ាងនេះជាច្រើនថ្ងៃ ។ ហេតុតែជាស្រីគ្រប់លក្ខណ៍នាងពៅនោះក៏ប្រណិប័តន៍ប្តីមិនឲ្យទាស់ចិត្ត វេលាយប់ចូលដំណេកនាងពៅនិយាយនឹងប្តីថា «ខ្ញុំសូមចិត្តប្តី ! តាំងពីថ្ងៃនេះតទៅ សូមអ្នកកុំទៅជីកក្តាមទៀតឡើយ ព្រោះប្រាក់កាសយើងមានច្រើនហើយ បើអ្នកចង់ទិញរបស់អ្វីៗ ក៏ទិញតាមចិត្តអ្នកចុះ » ។ ប្តីមិនព្រមតាម ។ លុះព្រឹកឡើង ប្តីកាន់ចបទៅជីកក្តាមទៀត ។ ប្រពន្ធឃើញដូច្នោះក៏លបដើរតាមទៅមើលដល់ទីកន្លែង ឲ្យឃើញច្បាស់មិនឲ្យដឹងលុះឃើញច្បាស់ហើយក៏ត្រឡប់មកផ្ទះវិញ ។ ចំណែកប្តីជីកបានក្តាមហើយយកទៅលក់ រួចទិញម្ហូបចំណីផ្ញើប្រពន្ធ ។ ថ្ងៃក្រោយប្តីទៅកាប់ឧសក្នុងព្រៃឆ្ងាយ នាងពៅបានឃើញប្តីទៅរកឧស ក៏កាន់ចបទៅជីករំលើង នៅទីកន្លែងដែលប្តីជីកក្តាមនោះអស់ រួចត្រឡប់មកផ្ទះដាំបាយធ្វើម្ហូបចំណីទុកឲ្យប្តីបរិភោគ , ថ្ងៃល្ងាចត្រជាក់ ប្តីមកពីព្រៃ ក៏បរិភោគបាយជាមួយគ្នា ។ លុះព្រឹកឡើង ប្តីកាន់ចបទៅជីកក្តាមទៀត ឃើញទីកន្លែងដីនោះធ្លុះធ្លាយរលើងរលុះខ្ទាត់ខ្ទាយអស់ ហើយបានឃើញសំបកក្តាមមួយធំប្លែកស្ងួតស្អាត ដូចជាហាលថ្ងៃយូរហើយ អ្នកនោះ ក៏កាន់សំបកក្តាមយកមកទុកក្រោមផ្ទះ មិនបានប្រាប់ភរិយាឲ្យដឹងទេ ភរិយាក៏សួរប្តីថាដូចម្តេចឡើយ ។ ដល់វេលាយប់ចូលដំណេក នាងពៅកាន់ប្រាក់របូតពីដៃជ្រុះមួយណែនទៅក្រោមផ្ទះ ធ្លាក់ទៅលើសំបកក្តាមនោះ នាងមិនហ៊ានប្រាប់ឲ្យប្តីដឹង ដោយគិតថា « ចាំព្រឹកភ្លឺច្បាស់ឡើង សឹមចុះទៅយកប្រាក់មកទុកវិញ» ។ លុះព្រឹកឡើង នាងចុះពីផ្ទះទៅយកប្រាក់មួយណែនដែលធ្លាក់នោះ ស្រាប់តែឃើញប្រាក់ណែនពេញសំបកក្តាម នាងអរណាស់ យកមកឲ្យប្តីៗសួរថា « នាងបានប្រាក់ពីណាច្រើនម្ល៉េះ ? ។ នាងពៅជម្រាបប្តីថា « កាលពីយប់មិញ ខ្ញុំកាន់ប្រាក់ដើម្បីយកទៅទុកខាងក្នុង ក៏របូតមួយណែនពីដៃ ធ្លាក់ទៅក្រោមផ្ទះ ខ្ញុំពុំបានចុះទៅយក ពីព្រោះគិតឃើញថា «ផ្ទះនៅឆ្ងាយពីគេ គ្មាននរណាដឹងឬឃើញ ចាំព្រឹកភ្លឺច្បាស់សឹមចុះទៅយកមកទុក ខ្ញុំចុះទៅយកស្រាប់តែឃើញប្រាក់ណែនពេញសំបកក្តាម ខ្ញុំក៏យកមកជូនអ្នក»។ ប្តីមានអំណរពន់ប្រមាណ ហើយនិយាយប្រាប់ប្រពន្ធថា «ពីថ្ងៃនេះតទៅ បងឈប់ជីកក្តាមហើយ » ។ ប្រពន្ធអរណាស់ រាល់តែវេលាយប់ អ្នកទាំងពីរនាក់ប្តីប្រពន្ធនាំគ្នាទម្លាក់ប្រាក់ទៅចំសំបកក្តាមធំ ព្រឹកឡើងចុះទៅមើល ឃើញប្រាក់ពេញសំបកក្តាមនោះ ក៏យកមកទុករៀងរាល់ថ្ងៃ ទើបទម្លាក់ប្រាក់រៀល ព្រឹកឡើងឃើញប្រាក់រៀល ទើបទម្លាក់ប្រាក់ណែន ព្រឹកឡើងឃើញប្រាក់ណែនទើបទម្លាក់គ្រឿងមាសពេជ្រ ព្រឹកឡើងឃើញគ្រឿងមាសពេជ្រ ពេញសំបកក្តាម ។ អ្នកទាំងពីរប្រព្រឹត្តយ៉ាងនេះចំនួនមួយឆ្នាំមានប្រាក់មាស និងគ្រឿងប្រដាប់ប្រើប្រាស់ ច្រើនណាស់រាប់មិនអស់ ទើបប្រឹក្សាគ្នាថា «យើងមានប្រាក់មាស និងគ្រឿងប្រដាប់ច្រើនម្ល៉េះ តើយើងបានអ្វីនឹងទុករបស់ទាំងអស់នេះ ?» លុះគិតឃើញ ក៏នាំគ្នាយកប្រាក់ និងគ្រឿងមាសពេជ្រទាំងអស់ទៅជីកកប់ទុកច្រើនអន្លើ ។ ក្រោយពីនោះមក ទាំងពីរនាក់ប្តីប្រពន្ធនាំគ្នាទៅសួរមហាសេដ្ឋីជាមាតាបិតា ទៅដល់បងស្រីទាំងអស់បានឃើញជេរថា «មេចោរចង្រៃឯង នាំប្តីកម្សត់លក់តែក្តាមមករកអ្វី ? ហាងឯងបានឮឬទេ លោកឪពុកបណ្តេញកាត់កាល់ចោលហើយ សូម្បីតែក្នុងភូមិ ក៏លោកហាមមិនឲ្យចូលដែរ ? មេចង្រៃឯងចេញពីភូមិឲ្យឆាប់ >> ។ នាងពៅឆ្លើយថា « បងទាំងអស់កុំមើលងាយខ្ញុំៗមកនេះដើម្បីសួរមាតាបិតាព្រោះលោកមានគុណលើខ្ញុំៗ មិនមកសុំទ្រព្យសម្បត្តិលោកទេ, សម្បត្តិបងឯងទាំងអស់ ក៏ខ្ញុំមិនសុំដែរ ខ្ញុំមើលទៅទ្រព្យសម្បត្តិបងទាំងអស់មានប៉ុណ្ណោះ ខ្ញុំមិនកោត មិនព្រឺឡើយ សូម្បីតែរោមជើងខ្ញុំ ក៏វាមិនព្រឺផង >> ។ បងទាំងអស់ខឹងណាស់ ជេរប្រទេចថា «ហាងឯងនេះអួតណាស់ អញមិនជឿទេ» ។ នាងពៅថា «បើមិនជឿ ភ្នាល់គ្នាចុះ» ។ បងទាំងនោះថា «ភ្នាល់ដូចម្តេច?»។ នាងពៅថា «ឲ្យបងទាំងអស់រាប់ប្រាក់ខ្ញុំមើល ឲ្យអស់ក្នុងមួយថ្ងៃ បើរាប់អស់ ខ្ញុំបែងចែកឲ្យរាល់គ្នា បើរាប់មិនអស់ ខ្ញុំមិនឲ្យទេ តែខ្ញុំយល់ថា កុំថាឡើយរាប់មួយថ្ងៃ ទោះជារាប់ពីរឬបីថ្ងៃ ក៏មិនអស់ដែរ» ។ បងទាំងនោះឆ្លើយថា «អញព្រមទៅរាប់ តែហាងកុំកុហក អញវាយហាងសម្លាប់ » ។ នាងពៅប្រាប់ថា « តាមចិត្ត » ។ បងៗនាំគ្នាទៅរាប់ប្រាក់នាងពៅ រាប់តាំងពីព្រឹកទល់ល្ងាចក៏មិនអស់ នាំគ្នាត្រឡប់មកផ្ទះវិញជម្រាបសេដ្ឋីជាមាតាបិតាថា «នាងពៅជាប្អូនវាអួតថាខ្លួនវាមានប្រាក់ច្រើន ខ្ញុំទាំងអស់គ្នាមិនជឿ ហើយវាថាបើមិនជឿ ឲ្យទៅមើលឯផ្ទះវាចុះ ខ្ញុំទាំងអស់គ្នាក៏ទៅមើល ឃើញវាមានប្រាក់ច្រើនមែន ក៏ភ្នាល់នឹងវាៗថា បើខ្ញុំទាំងអស់គ្នារាប់ប្រាក់វាអស់ក្នុងមួយថ្ងៃ វានឹងឲ្យខ្ញុំយកចែកគ្នាចុះ បើរាប់មិនអស់វាមិនឲ្យទេ ទោះខ្ញុំទាំងអស់គ្នា ចាប់រាប់តាំងពីព្រឹកទាល់ល្ងាច ក៏មិនអស់ប្រាក់វា បានជាត្រឡប់មកជម្រាបមាតាបិតាសូមជ្រាប» ។ មហាសេដ្ឋីបានស្តាប់ ក៏ចាត់ក្រមការឲ្យទៅមើលប្រាក់នាងពៅឲ្យជាក់ច្បាស់ ។ នាងពៅក៏នាំទៅមើលគ្រប់កន្លែង ។ ក្រមការទាំងនោះបានឃើញប្រាក់នាងពៅ មានច្រើនប្រាកដមែន ក៏ត្រឡប់មកជម្រាបមហាសេដ្ឋីតាមដំណើរសព្វគ្រប់ ។ មហាសេដ្ឋីបានជ្រាបមានចិត្តត្រេកអរណាស់ក៏ចាត់បម្រើឲ្យទៅហៅនាងពៅ និងកូនប្រសាមកប្រាប់ថា «កូនឯងមកនៅជាមួយនឹងមាតាបិតាវិញចុះ» ទើបមហាសេដ្ឋីបង្គាប់ក្រមការឲ្យកេណ្ឌរទេះក្របីគោជាច្រើន ទៅដឹកជញ្ជូនប្រាក់និងទ្រព្យសម្បត្តិនាងពៅ យកមកទាំងអស់ ដាក់លើផ្ទះពាសពេញល្វែង ។ មហា

សេដ្ឋីឃើញប្រាក់នាងពៅច្រើនមែន មានអំណរពន់ប្រមាណ ក៏សរសើរថា « កូនអញនេះពេញជាមានបុណ្យ អំណឹះតទៅកូនទាំងពីរនឹងបានធ្វើជាសេដ្ឋីដំណវង្សពុំខាន ឯការណ៍ដែលបិតាខឹងបណ្តេញកូននោះ អ្នកកុំប្រកាន់ខឹងនឹងបិតា » ។ នាងពៅនិងប្តីក៏នៅផ្ទះជាមួយមាតាបិតាដូចដើមវិញ ។ ចំណែកបងស្រីទាំងប៉ុន្មានក៏កោតខ្លាចនាងពៅ និងប្អូនថ្លៃនោះណាស់ ។ លុះមហាសេដ្ឋីជាបិតាទទួលមរណភាពទៅវេលាណា ប្តីនោះនិងនាងពៅភរិយា ក៏បានឡើងធ្វើជាសេដ្ឋីជំនួសបិតាតទៅ ។

> ***ឈើពុក កុំដាក់គូថអង្គុយ***

កម្ពុជសុរិយា លេខ ៧ – ៨ – ៩ ឆ្នាំ ១៩៣៩ ទំព័រ ២៥៧ រៀបរៀងដោយ ឧកញ៉ា ប្រាជ្ញាធិបតី ចាងហ្វាងយិន ។


g+1 +2 Recommend this on Google

# Wunsch-Domains bei STRATO

Die Domain mit den gewissen Extras. Bis 02.08. zum Top-Hoster wechseln!


ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ

